## ៦ ករណីសិក្សាពិស្តារ

## ឧបករណ៍គណនេយ្យភាពសង្គម

# សវនកម្មសង្គម



# សវនកម្មសង្គម

ៜៜ✵ៜៜ

**មាតិកា :** **ទំព័រ**

១.និយមន័យ ........ ៣
២.គោលបំណង ........ ៣
៣.ដំណើរការអនុវត្ត ........ ៤
៤.តើសវនកម្មសង្គមបានអនុវត្តនៅកន្លែងណាខ្លះ? ........ ៦
៥.ចំណុចខ្លាំង និងការប្រឈម ........ ៧
៦.ខ្លឹមសារមេរៀន: ........ ៨

# សវនកម្មសង្គម (Social Audit)

សវនកម្មសង្គម (នៅពេលខ្លះក៏ត្រូវបានគេហៅថា គណនេយ្យសង្គមផងដែរ (Social Accounting) ) ជាដំណើរ ប្រមូលព័ត៌មានពីធនធានរបស់អង្គភាពមួយ។ ព័ត៌មានត្រូវវិភាគ និងចែកចាយជាសាធារណៈ តាមលក្ខណៈការចូលរួមមួយ។ ទោះជា ពាក្យ "សវនកម្ម" ត្រូវបានយកមកប្រើ សវនកម្មសង្គមមិនពាក់ពន្ធ័នឹង ការត្រួតពិនិត្យហិរញ្ញវត្ថុនោះទេ។ សវនកម្មសង្គមផ្តោតជាសំខាន់ថាតើ ធនធានត្រូវបានប្រើប្រាស់ចំគោលបំណង សង្គមបានយ៉ាងដូចម្តេច។

## ១. និយមន័យ

សវកម្មសង្គម ជាដំណើរការដែលបង្កើតឡើងដោយប្រជាពលរដ្ឋក្រោមការសម្របសម្រួលជាមួយរដ្ឋបាល មូលដ្ឋាន ដើម្បីធានាឱ្យប្រជាពលរដ្ឋទទួលបានព័ត៌មានលម្អិតពីការប្រើប្រាស់ធនធាន (ទាំងហិរញ្ញវត្ថុ និងមិនមែន ហិរញ្ញវត្ថុ) ដែលប្រើប្រាស់ដោយភ្នាក់ងារសាធារណៈសម្រាប់ផ្តួចផ្តើមការអភិវឌ្ឍ។ សវនកម្មសង្គមជាធម្មតាធ្វើ ជាទម្រង់ វេទិកាសាធារណៈ។

## ២. គោលបំណង

ដែនកំណត់របស់សវនកម្មសង្គមមានភាពខុសៗគ្នា។ ដែនកំណត់អាចប្រើសម្រាប់ស៊ើបអង្កេតកិច្ចការរបស់ នាយកដ្ឋានរដ្ឋាភិបាល ដោយប្រើពេលច្រើនឆ្នាំនៅក្នុងស្រុកមួយចំនួន។ ដែនកំណត់អាចប្រើប្រាស់ផងដែរដើម្បី គ្រប់គ្រង គម្រោងជាក់លាក់មួយនៅក្នុងភូមិមួយតាមពេលវេលាកំណត់។ សវនកម្មភាគច្រើនជាធម្មតាមាន សកម្មភាព និងលទ្ធផលដូចខាងក្រោម:

- បង្កើតព័ត៌មានដែលមានភស្តុតាងជាមូលដ្ឋាន ទាន់ហេតុការណ៍និង មិនលំអៀង
- បង្កើតការយល់ដឹងក្នុងចំណោមអ្នកទទួល និងអ្នកផ្តល់សេវានៅមូលដ្ឋាន
- ធ្វើឱ្យប្រសើរឡើងនូវការទទួលបានព័ត៌មានរបស់ពលរដ្ឋពាក់ព័ន្ធឯកសាររបស់រដ្ឋាភិបាល
- ជាឧបករណ៍មានតម្លៃសម្រាប់បង្ហាញឱ្យឃើញពីអំពើពុករលួយ និងការគ្រប់គ្រងមិនបានល្អ
- ផ្តល់ឱកាសឱ្យអ្នកពាក់ព័ន្ធមានឥទ្ធិពលទៅលើឥរិយាបទរបស់រដ្ឋាភិបាល និង
- ពិនិត្យតាមដានដំណើរការ និងជួយការពារមិនឱ្យមានការលួចបន្លំ ។

៣. ដំណើរការអនុវត្ត

វិធីសាស្ត្រសវនកម្មសង្គមមានភាពផ្សេងៗគ្នា និងទទួលឥទ្ធិពលពីកត្តាដូចខាងក្រោម: បរិបទប្រទេស ព័ត៌មានដែលអាចទទួលបាន និងក្របខ័ណ្ឌច្បាប់និងនយោបាយ។ ជាទូទៅសវនកម្មសង្គម រួមបញ្ចូលនូវជំហានមួយចំនួនដូចខាងក្រោម:

***ក.កំណត់គោលបំណង***

គោលបំណងរបស់សវនកម្មសង្គមគួរតែគូសបញ្ជាក់ឱ្យបានច្បាស់លាស់។ ជាដំបូង ត្រូវកំណត់នូវភ្នាក់ងារ/គម្រោងដែលជាប់ពាក់ព័ន្ធដែលនឹងត្រូវធ្វើសវនកម្ម។

***ខ.កំណត់អ្នកជាប់ពាក់ព័ន្ធ***

អ្នកពាក់ព័ន្ធគួរតែកំណត់ និង រួមបញ្ចូលទៅក្នុងដំណើរការទាំងមូល។ អ្នកពាក់ព័ន្ធគួរមានសមាសភាពមកពីតួអង្គពាក់ពន្ធ័របស់រដ្ឋាភិបាលដូចជា អ្នកផ្ដល់សេវា/ឬអ្នកទទួលកិច្ចសន្យា តំណាងសង្គមស៊ីវិល អ្នកទទួលផល និងកម្មករ របស់អ្នកផ្ដល់សេវា។ ក្រុមដែលមានតំណាងតិចតួចនៅក្នុងសង្គម គួរត្រូវទទួលបានការរាប់បញ្ចូលផងដែរ។

***គ.ការប្រមូលទិន្នន័យ***

សវនកម្មសង្គមប្រើប្រាស់ វិធីសាស្ត្រប្រមូលទិន្នន័យផ្សេងៗរួមបញ្ចូលគ្នាសម្រាប់ទទួលបានទិន្នន័យជាប់ពាក់ព័ន្ធ រួមមានទាំង*ការសម្ភាសន៍ ការស្ទាបស្ទង់មតិ ការសាកល្បងពិនិត្យគុណភាព ការបកស្រាយស្ថិតិ ករណីសិក្សា ការអង្កេតដោយចូលរួម ការវាយតម្លៃជាបន្តបន្ទាប់ ប្រមូលកំណត់ត្រាជាផ្លូវការដែលពាក់ព័ន្ធ និងដកស្រង់ព័ត៌មានពាក់ព័ន្ធពីប្រភព ទិន្នន័យផ្សេងៗដែលមានស្រាប់*។ នេះជាដំណាក់កាលសំខាន់នៅក្នុងដំណើរការ ប៉ុន្តែមានលក្ខណៈពិបាកនិងបញ្ហាប្រឈមច្រើន ពីព្រោះភ្នាក់ងារដែលត្រូវស៊ើបអង្កេតអាចគ្មានឯកសារ កត់ត្រាត្រឹមត្រូវ ឬអាចគ្មានឆន្ទៈផ្ដល់កំណត់ត្រាទាំងនោះ។ ការរួមបញ្ចូលមន្ត្រីដែលមកពី ភ្នាក់ងារផ្សេងៗដែលគេកំពុងវាយតម្លៃឱ្យចូលរួមពិតជាមានសារសំខាន់ណាស់ ពីព្រោះពួកគេមានឆន្ទៈផ្ដល់ព័ត៌មាន នេះប្រសិនបើពួកគេបានចូលរួម និងយល់ដឹងពីសក្ដានុពលអត្ថប្រយោជន៍នៃដំណើរការទាំងមូល។

ការធ្វើការសាកល្បងពិនិត្យគុណភាព អាចត្រូវចំណាយខ្ពស់ ហើយមិនអាចទទួលបានផលទេបើថវិកាមានកំណត់។ ការសាកល្បងពិនិត្យគុណភាពអាចធ្វើលើ (ឧ: សាកល្បងលើគុណភាពស៊ីម៉ងដែលបានប្រើក្នុងសំណង់មួយ ឬការលាយកៅស៊ូធ្វើផ្លូវ)។ ករណីទាំងនេះបានបង្កើតនូវភស្តុតាងជាក់ស្ដែងពីការប្រើប្រាស់ធនធានខុស។

ដំណើរការប្រមូលទិន្នន័យ គឺមានទំហំធំ និងចំណាយ ពេលវេលាច្រើនផងដែរ។ គណកម្មាធិការសវនកម្មក្នុងសហគមន៍និមួយៗអាចទទួលបន្ទុក សម្ភាសន៍តំណាងៗ ដូចជា អភិបាលក្រុង ប្រធានលទ្ធកម្ម

អង្គភាពទទួលបន្ទុកធ្វើកិច្ចសន្យា និងសម្រាប់មើលទីតាំង (ផ្លូវ អាគារជាដើម) និងសម្រាប់ប្រមូលព័ត៌មានពីលទ្ធផលគម្រោងទាំងមូល។

### ឃ.ការវិភាគទិន្នន័យ

ការបកស្រាយកំណត់ត្រាជាផ្លូវការ អាចជួបឧបសគ្គ និងមានភាពស្មុគស្មាញ។ ព័ត៌មានប្រមូលបានតាមរយៈវិធីសាស្ត្រផ្សេងៗគ្នា និងប្រភពខុសៗគ្នាគួរតែសង្ខេបទុកក្នុងឯកសារទូទៅមួយ ដែលអ្នកពាក់ព័ន្ធនឹងដំណើរការនេះគ្រប់ៗរូបអាចយល់បានដោយងាយ។ សម្រាប់ទិន្នន័យត្រូវធ្វើឱ្យកាន់តែងាយយល់។

### ង.ការចែកចាយ និងទទួលព័ត៌មានត្រឡប់ពីព័ត៌មានទទួលបាន

លទ្ធផលបានមកពីសវនកម្ម ត្រូវផ្ដល់ឱ្យទៅអ្នកពាក់ព័ន្ធទាំងអស់សម្រាប់ទទួលព័ត៌មានត្រឡប់។ ពលរដ្ឋដែល បានធ្វើការក្នុងតំបន់គម្រោងដើរតួយ៉ាងសំខាន់ក្នុងដំណាក់កាលនេះ ដោយហេតុតែពួកគេអាចផ្ទៀងផ្ទាត់ទូរលេខ ទាក់ទងនៅនឹង ធនធានសម្ភារៈ និងធនធានមិនមែនសម្ភារៈដែលលើកឡើងនៅក្នុងឯកសារគម្រោង។ ការផ្លាស់ប្ដូរព័ត៌មាននេះ បានផ្ដល់ឱកាសសម្រាប់កសាងចលនាប្រជាពលរដ្ឋ និងឱ្យសាធារណៈធ្វើការកាត់សេចក្ដីដោយចំហ។ ការផ្ដួចផ្ដើមធ្វើ សវនកម្មសង្គមមួយចំនួន បានប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយដោយច្នៃប្រឌិត ដូចជាចម្រៀង ការសំដែងតាមផ្លូវ ការចងបជាសម្រាប់ពន្យល់ពីដំណើរការ និងផ្សព្វផ្សាយសម្រាប់ធ្វើការសវនាការសាធារណៈ (public hearing)។

### ច. សវនការសាធារណៈ (Public Hearing)

នៅក្នុងតំបន់ធំ សវនការសាធារណៈគួររៀបចំឡើងឱ្យបានច្រើនដង ព្រោះទីតាំងដែលមានភាពងាយស្រួល និងអាចចូលរួមបានពីគ្រប់សមាសភាពទាំងអស់ពិតជាមានភាពចាំបាច់ណាស់។ នៅដើមសវនការ បទបញ្ជាផ្ទៃក្នុង (rules of conduct) ត្រូវពន្យល់អ្នកចូលរួមដើម្បីជៀសវាងជម្លោះ។ បន្ទាប់មកក្រុមការងារ ឬអ្នកស្រុកត្រូវរៀបរាប់ លទ្ធផលរបស់សវនកម្មសង្គម ដែលរួមមានទាំងភស្ដុតាងនៃអំពើពុករលួយ អប្រសិទ្ធភាពក្នុងការប្រើប្រាស់ មូលនិធិ ឬការធ្វើផែនការមិនបានល្អ មន្ត្រីសាធារណៈបានផ្ដល់ឱកាសគ្រប់គ្រាន់សម្រាប់កែប្រែទង្វើរបស់ពួកគេក្នុងគម្រោងជាដើម។ ក្រុមដែលមានតំណាងតិចគួរលើកទឹកចិត្តឱ្យបញ្ចេញយោបល់របស់ពួកគេយ៉ាងសកម្ម។

### ឆ. ការត្រួតពិនិត្យតាមដាន

បន្ទាប់ពីសវនាការសាធារណៈ របាយការណ៍ចុងក្រោយរបស់សវនកម្មសង្គមនិងត្រូវសរសេរឡើង។ របាយការណ៍ នេះរួមបញ្ចូលទាំងអនុសាសន៍សម្រាប់រដ្ឋាភិបាលដែលលើកឡើង ជាឧទាហរណ៍ជាក់ស្ដែងពីអំពើពុករលួយ និងការគ្រប់គ្រងមិនបានត្រឹមត្រូវ។ របាយការណ៍គួរផ្សព្វផ្សាយឱ្យបានទូលំទូលាយទៅដល់ មន្ត្រីរដ្ឋាភិបាល ប្រព័ន្ធផ្សព្វផ្សាយ អ្នកចូលរួមដែលជាប់ពាក់ព័ន្ធនៅក្នុង ដំណើរការ និងអង្គភាព ជាប់ពាក់ព័ន្ធនានា។ លទ្ធផលចម្បងៗ និងសកម្មភាពជា អនុសាសន៍គួរផ្សព្វផ្សាយជាលាយលក្ខអក្សរ និងផ្សព្វផ្សាយពីម្នាក់ទៅម្នាក់។

## ៨.តើអ្នកណាជាអ្នកអនុវត្តសវនកម្មសង្គម?

ជំហានសវនកម្មដូចអធិប្បាយខាងលើមានភាពខុសគ្នាៗអាស្រ័យលើភ្នាក់ងារ និងធនធានដែលមានជាក់ស្តែង។ នៅបណ្តាប្រទេសមួយចំនួន រដ្ឋាភិបាលធ្វើសវនកម្មសង្គមសម្រាប់វាយតម្លៃខ្លួនឯងយ៉ាងទៀងទាត់។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងប្រទេសកំពុងអភិវឌ្ឍជាច្រើន អង្គការសង្គមស៊ីវិលបានផ្តួចផ្តើមដំណើរការសវនកម្មសសង្គម ដើម្បីឱ្យរដ្ឋាភិបាលមានការទទួលខុសត្រូវលើសកម្មភាពរបស់ខ្លួន។ យោងទៅតាមដែនកំណត់របស់សវនកម្ម អង្គការសង្គមស៊ីវិលផ្សេងៗ ស្ថាប័នស្រាវជ្រាវ ឬភ្នាក់ងាររដ្ឋាភិបាលអាចធ្វើការងាររួមគ្នាដោយស្ថិតក្រោមទិសដៅនៃស្ថាប័នដឹកនាំតែមួយ។ ជម្រើសរបស់ភ្នាក់ងារអនុវត្តមានសារ សំខាន់បំផុតចំពោះជោគជ័យនៃដំណើរការសវនកម្ម។ អង្គភាពត្រូវបានគេមើលឃើញថាសំខាន់ និងមិនលំអៀងខាងគណបក្សដែលជាប់ពាក់ព័ន្ធក្នុងដំណើរការ។

៨. តើសវនកម្មសង្គមបានអនុវត្តនៅកន្លែងណាខ្លះ?

សវនកម្មសង្គមត្រូវបានអនុវត្តនៅប្រទេសជាច្រើន។ ពេលខ្លះ សវនកម្មសង្គមត្រូវបានប្រើដើម្បីស៊ើបអង្កេត ពីគុណភាពសេវា ដូចជា នគរបាល គយ ឬសាលារៀន បើទោះជាកិច្ចការចម្បងរបស់សវនកម្មសង្គមផ្តោតទៅលើ កិច្ចការសាធារណៈ។ ពេលវេលាសម្រាប់ការស៊ើបអង្កេតមានរយៈពេលចាប់ពីពីរទៅប្រាំឆ្នាំ។ សវនកម្មសង្គមត្រូវបានប្រើបន្ទាប់ពីបញ្ចប់ គម្រោងនិងអំឡុងពេលដំណាក់កាលធ្វើផែនការ ឬដំណាក់កាលអនុវត្ត។ សវនកម្មអំឡុងពេលដំណាក់កាលធ្វើ ផែនការ និងអនុវត្តជាធម្មតាមិនសូវបានផលទេ ពីព្រោះតម្រូវឱ្យមានកិច្ចសហប្រតិបត្តិការជិតស្និទ្ធជាមួយភ្នាក់ងាររដ្ឋាភិបាល ដែលត្រូវធ្វើសវនកម្ម។ ទោះជាយ៉ាងណាក៏ដោយ បើអាចធ្វើបាន សវនកម្មអំឡុងពេលដំណាក់កាលធ្វើផែនការ មានអត្ថប្រយោជន៍រារាំងមិនឱ្យមានសកម្មភាពមិនត្រឹមត្រូវណាមួយ តាមរយៈការពិនិត្យតាមដានលើការធ្វើសេចក្តីសំរេចចិត្ត ការដេញថ្លៃ ការធ្វើកិច្ចសន្យា និងការប្រតិបត្តិ។ សវនកម្មសង្គម ធ្វើឡើងក្រោយពីគម្រោងបានបញ្ចប់អាចត្រូវធ្វើដោយឯករាជ្យដោយឆន្ទៈខ្លាំងក្លារបស់ភ្នាក់ងារក្រោមការពិនិត្យពិច័យ បើទោះជាតែងតែតម្រូវឱ្យមានកិច្ចសហប្រតិបត្តិការជាអប្បបរមាដើម្បីទទួលបានឯកសារចាំបាច់ ជាពិសេសប្រសិន បើគ្មានមធ្យោបាយទទួលបានព័ត៌មានដោយស្របច្បាប់។

ការងារសវនកម្មសង្គមបានបង្កើតនូវលទ្ធផលដូចខាងក្រោម:

- ការងារទូទាត់ប្រាក់ឱ្យ តែពុំទាន់ធ្វើនៅឡើយ ដូចជា ផ្លូវឬអណ្តូងទឹកមានតែនៅលើក្រដាស
- ការងារធ្វើបានដោយអន្លើៗ (មានតែការងារមួយភាគក្នុងរបាយការណ៍ដែលបានធ្វើ ឬមានតែការងារមួយភាគក្នុងការព្រមព្រៀងត្រូវបានបំពេញ)

- គុណភាពការងារដែលធ្វើហើយអន់ជាងក្នុងកិច្ចសន្យា
- ការងារដែលបញ្ចប់មានវិក័យបត្រពីរ និងការទូទាត់ចំណាយពីរដង
- បញ្ជីខ្មោច រួមមាន "កម្មករខ្មោច" (ឈ្មោះមនុស្សស្លាប់ហើយ ដែលចាកចេញពីភូមិ មិនដែលធ្វើការងារក្នុងគម្រោង មានឈ្មោះក្នុងបញ្ជីបើកប្រាក់ខែ)
- ប្រាក់ឈ្នួលការងារទាបជាងការកត់ត្រាក្នុងរបាយការណ៍

៥. ចំណុចខ្លាំង និងការប្រឈម

| ចំណុចខ្លាំង | ការប្រឈម |
|---|---|
| ធ្វើឱ្យប្រសើរឡើងនូវតម្លាភាពការងារ/សេវាសាធារណៈ | រារាំងការចាប់យកឱកាសរបស់ក្រុមមាន ឈ្មោះល្បី |
| រាយការណ៍និងកាត់បន្ថយអំពើពុករលួយ និងការចាត់ចែងខុស | រដ្ឋាភិបាលគ្មានកាតព្វកិច្ចស្របច្បាប់ ក្នុងការបញ្ចេញប្រតិកម្មចំពោះលទ្ធផល |
| ធ្វើឱ្យគុណភាពការងារ/សេវាសាធារណៈប្រសើរឡើង | ដំណើរការត្រូវការពេលវេលា តម្លៃ និងកិច្ចខិតខំប្រឹងប្រែងខ្លាំងក្លារបស់អង្គភាព |
| ពង្រឹងសមត្ថភាពសហគមន៍ក្នុងការធ្វើផែនការដោយមាន ការចូលរួម | សមត្ថភាពរៀបចំមតិយោបល់របស់អ្នកពាក់ព័ន្ធ |

***ការប្រឈមផ្សេងៗទៀត: ធានានូវភាពជឿជាក់របស់ទិន្នន័យ និងប្រើប្រាស់ទិន្នន័យដោយខុសច្បាប់:***

គុណភាពទិន្នន័យដែលប្រមូលបាន និង ការយល់ឃើញពីរបៀបរៀបចំដោយមិនលំអៀងមានសារសំខាន់ចំពោះដំណើរការដោយរលូននឹងផ្អែកទៅលើកត្តាជាច្រើន:

- ទិន្នន័យគួរតែប្រមូលជាប្រព័ន្ធ និងស៊ីសង្វាក់នឹងគ្រួសារ សហគមន៍ និង ការឃ្លាំមើលគម្រោង/សេវា
- ដើម្បីធានាសុក្រិតភាព ត្រូវបណ្តុះបណ្តាលអ្នកប្រមូលទិន្នន័យ ដូច្នេះពួកគេអាចអនុវត្តវិធីសាស្ត្រប្រមូលទិន្នន័យបានល្អ
- ការបណ្តុះបណ្តាលពិសេសមានភាពចាំបាច់ណាស់សម្រាប់ពង្រឹងការយល់ដឹងផ្នែកបច្ចេកទេសដល់អ្នកប្រមូលទិន្នន័យ ដូចជាពីដំណើរការដេញថ្លៃ ច្បាប់កិច្ចសន្យា ឬពីថវិការគម្រោងជាដើម។
- ធ្វើឱ្យប្រាកដថាក្រុមផ្សេងៗគ្នាទាំងអស់ត្រូវបានរាប់បញ្ចូល
- បញ្ចូលកំណត់ត្រាទិន្នន័យផ្លូវការដែលពាក់ព័ន្ធ និងអាចរកបាន

- តំបន់ជនបទក្រីក្រត្រូវតែទទួលបានការការពារ ដូច្នេះពួកគេគ្មានការភ័យខ្លាចពេលលើកឡើងពីកង្វល់នានារបស់ពួកគេ
- មុនពេលផ្សព្វផ្សាយលទ្ធផលជាសាធារណៈ ត្រូវត្រួតពិនិត្យភាពសុក្រិតភាព និង សុពលភាពទិន្នន័យ
- ជៀសវាងទម្លាក់កំហុសលើភាគីណាមួយៈ សវនកម្មសាធារណៈបង្កើតឡើងសម្រាប់ផ្តោតលើប្រពន្ធ័និងកម្មវិធីជាជាងផ្តោតលើបុគ្គល ឬអង្គភាព
- ជ្រើសរើសប្រជាពលរដ្ឋសហគមន៍ដែលគេគោរព និងអព្យាក្រិតមិនលំអៀងខាងគណបក្សនយោបាយឱ្យធ្វើជាអ្នកសម្របសម្រួលសម្រាប់សវនកម្មសាធារណៈ
- ប្រយ័តមិត្តភ័ក្រដែលមន្ត្រីសូកប៉ាន់ឱ្យលាក់កំបាំងព័ត៌មាន ឬគំរាមអ្នកស្រុកមិនឱ្យផ្តល់ព័ត៌មានពាក់ព័ន្ធនានា

៦. ខ្លឹមសារមេរៀនៈ

សវនកម្មសង្គមដើរតួទាំងជាឧបករណ៍ពិនិត្យតាមដាននិងជាឧបករណ៍វាយតម្លៃៈ

- **ជាឧបករណ៍ពិនិត្យតាមដានៈ** សវនកម្មសង្គមជាឧបករណ៍ត្រួតពិនិត្យ តាមដានសំខាន់មួយ ហើយអាចប្រើប្រាស់បានទាំងនៅដំណាក់កាលណាមួយកំឡុងពេលអនុវត្តគម្រោង និងក្រោយពេលអនុវត្តគម្រោង ដើម្បីប៉ាន់ ប្រមាណលទ្ធផលចុងក្រោយរបស់គម្រោង។
- **ជាឧបករណ៍វាយតម្លៃៈ** សវនកម្មសង្គមដែលអនុវត្តរួមគ្នាជាមួយអ្នកសម្របសម្រួលខាងក្រៅ និងសហគមន៍មូលដ្ឋាន អាចហៅថាការវាយតម្លៃ ដោយមានការចូលរួម។
- សវនកម្មសង្គមនាំមកនូវសច្ចធម៌ជូនអ្នកពាក់ព័ន្ធ